ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................................

# សេចក្តីប្រកាសព័ត៌មាន ស្តីពី
# ការស្រាវជ្រាវរួមគ្នាក្រោមកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹង" ឆ្នាំ២០១៨
# រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលកូរ៉េ លើប្រធានបទ
# "ទំនាក់ទំនងរវាងម៉ាក្រូសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ ៖ ការវិភាគ និងការអនុវត្ត សម្រាប់បរិបទសេដ្ឋកិច្ចកម្ពុជា"

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨

កាលពីថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការស្រាវជ្រាវរួមគ្នាក្រោមកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹង" ឆ្នាំ២០១៨ លើប្រធានបទ "ទំនាក់ទំនងរវាងម៉ាក្រូសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ ៖ ការវិភាគ និងការអនុវត្តសម្រាប់បរិបទសេដ្ឋកិច្ចកម្ពុជា"។ កម្មវិធីត្រូវបានរៀបចំឡើងក្រោមអធិបតីភាព លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា និងលោក Seung Hee LEE អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានកិច្ចការអន្តរជាតិនៃធនាគារកណ្តាលកូរ៉េ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា គណៈប្រតិភូធនាគារកណ្តាលកូរ៉េ និងសាស្ត្រាចារ្យពីសាកលវិទ្យាល័យ Yonsei ។

ការស្រាវជ្រាវរួមគ្នាក្រោមកម្មវិធីភាពជាដៃគូផ្តល់ចំណេះដឹងរបស់ធនាគារកណ្តាលកូរ៉េ (BOK-KPP) នឹងផ្តល់ឱកាសឱ្យមន្ត្រីជំនាញធនាគារជាតិនៃកម្ពុជាបានសហការជាមួយអ្នកស្រាវជ្រាវនៃធនាគារកណ្តាលកូរ៉េ និងសាកលវិទ្យាល័យ Yonsei របស់ប្រទេសកូរ៉េ ដើម្បីពង្រឹងជំនាញផ្នែកវិភាគនិងការសិក្សានូវទំនាក់ទំនងរវាងម៉ាក្រូសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់ម៉ូដែលសេដ្ឋកិច្ច។

លទ្ធផលនៃការស្រាវជ្រាវនឹងក្លាយជាឯកសារស្រាវជ្រាវថ្មីមួយបន្ថែមទៀតសម្រាប់អ្នកស្រាវជ្រាវទូទៅ ហើយក៏ជាធាតុចូលក្នុងការរៀបចំគោលនយោបាយនានា ជាពិសេស ការរក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យរឹងមាំ សំដៅគាំទ្រការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជា។ គម្រោងស្រាវជ្រាវនេះរំពឹងថានឹងបញ្ចប់និងផ្សព្វផ្សាយនៅខែធ្នូ ឆ្នាំ២០១៨ ខាងមុខ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧